## ការវាយតម្លៃ និងលទ្ធផលព្យាករណ៍កំណើនសេដ្ឋកិច្ចកម្ពុជា ឆ្នាំ ២០២៥-២០២៨




*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (២០១៩-២០២២) និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០២៣-២០២៨)*

បើផ្អែកតាមទស្សនវិស័យសេដ្ឋកិច្ចរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បោះផ្សាយក្នុងខែ មេសា ឆ្នាំ ២០២៥, សេដ្ឋកិច្ចសកល ត្រូវបានវាយតម្លៃថានឹងសម្រេចបាននូវកំណើនថមថយជាងការរំពឹងទុកក្នុងរង្វង់ប្រមាណ ២,៨% ក្នុងឆ្នាំ ២០២៥ និង ៣,០% ក្នុងឆ្នាំ ២០២៦ ពោលគឺទាបជាងការវាយតម្លៃនៅខែ មករា កន្លងទៅ ដែលស្ថិតក្នុងរង្វង់ ៣,៣% ដូចគ្នា សម្រាប់ឆ្នាំ ២០២៥ និង ២០២៦ ។ ការណ៍នេះ ឆ្លុះបញ្ចាំងពីការរំពឹងទុកកម្មវិបាកជាអវិជ្ជមាននៃការកើនឡើងចរន្តគាំពារនិយម ដែលស្តែងចេញជាពិសេសតាមរយៈការដំឡើងពន្ធគយ (Broad-based tariff hike) និងពន្ធគយបដិការ (Reciprocal tariff), ដែលនឹងបន្ទប់បង្អាក់ដល់ចលនការនៃកំណើនសេដ្ឋកិច្ចរបស់បណ្តាប្រទេសជាច្រើន ដូចជាសហរដ្ឋអាម៉េរិក, សហភាពអឺរ៉ុប ចិន និង ប្រទេសអាស៊ាន ជាដើម ។

ស្រដៀងទៅនឹងទស្សនវិស័យសេដ្ឋកិច្ចសកល និងតំបន់ដែរ, សេដ្ឋកិច្ចកម្ពុជា រំពឹងថានឹងមានកំណើនថមថយ ក្នុងអត្រា ៥,២% ក្នុងឆ្នាំ ២០២៥ និង ៥,០% ក្នុងឆ្នាំ ២០២៦ ដោយសារការរំពឹងផលជះជាអវិជ្ជមាន ជាពិសេសមកលើវិស័យបម្រើការនាំចេញ, ពោលគឺទាបជាកំណើនឆ្នាំ ២០២៤ ដែលសម្រេចបាន ៦,០% នាពេលកន្លងទៅ ។ ក្នុងនោះ, វិស័យឧស្សាហកម្ម រំពឹងថានឹងមាននិន្នាការថមថយបន្តិច ជាមួយនឹងអត្រាកំណើន ៧,៨% និង ៧,១% ក្នុងឆ្នាំ ២០២៥ និង ២០២៦ រៀងគ្នា ដោយសារការថមថយសម្ទុះនៃកំណើនអនុវិស័យកាត់ដេរ បណ្តាលមកពីការស្រុតស្រុតតម្រូវការសកល ពោល

គឺការបញ្ជាទិញពីបណ្ដាប្រទេសដៃគូពាណិជ្ជកម្មរបស់កម្ពុជា ដែលជាបច្ច័យនៃការកើនឡើងយ៉ាងឆាប់រហ័សនៃចរន្តគាំពារនិយម មកលើសម្ទុះនៃកំណើនសេដ្ឋកិច្ចសកល ។ កំណើននៃអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ ក៏រំពឹងថាមានការថមថយជាងការរំពឹងទុក ជាពិសេសការនាំចេញទំនិញសំខាន់ៗ មួយចំនួនទៅសហរដ្ឋអាម៉េរិកដោយផ្ទាល់ តួយ៉ាងដូចជា គ្រឿងសង្ហារិម និងសំបកកង់រថយន្ត, ប៉ុន្តែ ជារួម, អនុវិស័យនេះក៏នៅបន្តរក្សាបានកំណើនវិជ្ជមាន ដែលបន្តជំរុញដោយការនាំចេញផលិតផលសំខាន់ៗ ផ្សេងទៀត ឧទា. គ្រឿងបង្គុំអេឡិចត្រូនិក ជាដើម, គួបផ្សំនឹងការរក្សាបាននូវចលនការនៃឧស្សាហកម្មបម្រើទីផ្សារក្នុងស្រុក តួយ៉ាងដូចជា ឧស្សាហកម្មដំឡើងរថយន្ត និងផលិតកម្មចំណីអាហារ និងភេសជ្ជៈ ។ អនុវិស័យសំណង់ នៅបន្តងើបឡើងក្នុងល្បឿនយឺតដូចការរំពឹងទុក ដែលបន្តទ្រទ្រង់ដោយសកម្មភាពសំណង់លំនៅឋាន និងសំណង់បម្រើឱ្យវិស័យឧស្សាហកម្ម ដូចជា រោងចក្រ និងឃ្លាំង ជាដើម ។ វិស័យសេវាកម្ម ក៏រំពឹងថានឹងមានកំណើនថមថយជាងការរំពឹងទុកផងដែរ ក្នុងអត្រាកំណើន ៣,៨% ដូចគ្នាក្នុងឆ្នាំ ២០២៥ និង ២០២៦ ដោយសារការថមថយនៃសម្ទុះកំណើនសកម្មភាពចាយវាយ និងប្រើ-ប្រាស់ក្នុងស្រុក (លក់ដុំ-រាយ) និងសកម្មភាពដឹកជញ្ជូន និងស្តុក ដោយសារការថមថយនៃចលនការកំណើនរបស់វិស័យទ្រទ្រង់ចំណូល ជាពិសេសវិស័យកាត់ដេរ, ប៉ុន្តែអនុវិស័យទាំងនេះ ជារួម នៅតែបន្តរក្សាបានកំណើនវិជ្ជមាន, ខណៈដែលអនុវិស័យបដិសណ្ឋារកិច្ច និងសេវាកម្មម្ហូបអាហារ (ទេសចរណ៍) ក៏នៅតែបន្តនិន្នាការកើនឡើង ដូចការគ្រោងទុក ។ វិស័យកសិកម្ម រំពឹងថានឹងបន្តរក្សាបានស្ថិរភាពនៃកំណើន ក្នុងអត្រា ០,៩% និង ១,០% ក្នុងឆ្នាំ ២០២៥ និង ២០២៦ រៀងគ្នា ដែលបន្តគាំទ្រដោយកំណើនល្អនៃអនុវិស័យដំណាំ ឆ្លុះបញ្ចាំងតាមរយៈការបន្តនិន្នាការល្អប្រសើរនៃការនាំចេញ កសិផលសំខាន់ តួយ៉ាងដូចជា ស្រូវ-អង្ករ, ស្វាយចន្ទី និងដំឡូងមី ជាដើម ។ ជាមួយគ្នានេះ, អនុវិស័យនេសាទក៏បន្តមានកំណើនល្អ ដែលជំរុញដោយនិន្នាការល្អនៃផលចាប់ទឹកសាប ស្របពេលដែលអនុវិស័យចិញ្ចឹមសត្វ ក៏ចាប់ផ្ដើមងើបឡើងវិញជាសន្សឹមៗ ដោយសារការរំពឹងទុកការចាប់ផ្ដើមងើបឡើងវិញនៃទំនុក-ចិត្តវិនិយោគ ស្របពេលរាជរដ្ឋាភិបាលនៅតែបន្តផ្ដល់ការយកចិត្តទុកដាក់ខ្ពស់លើវិធានការអន្តរាគមន៍ និងបទប្បញ្ញត្តិ ទាំងឡាយពាក់ព័ន្ធនឹងការនាំចូលសាច់បង្កក ដើម្បីគាំពារដល់ផលិតកម្មក្នុងស្រុក ។

អត្រាកំណើនពិតនៃសេដ្ឋកិច្ចខាងលើ បានធ្វើឱ្យ ផសស ថ្លៃបច្ចុប្បន្ន បន្តកើនដល់ ២០៦ ៣៩៦ ប៊ីលានរៀល និង ២២១ ៦៦៩ ប៊ីលានរៀល ក្នុងឆ្នាំ ២០២៥ និង ២០២៦ រៀងគ្នា, ស្របពេលដែល ផសស សម្រាប់មនុស្សម្នាក់ បន្តកើនឡើងដល់ប្រមាណ ២ ៨៩៦ ដុល្លារអាម៉េរិក និង ៣ ០៧១ ដុល្លារអាម៉េរិក ។ អត្រាអតិផរណា ងើបឡើងបន្តិច ក្នុងអត្រា ៣,០% ក្នុងឆ្នាំ ២០២៥ ដោយសារមូលដ្ឋានទាបក្នុងឆ្នាំចាស់ ដែលមានកំណើនក្នុងរង្វង់ ០,៨% តែប៉ុណ្ណោះ ក្នុងឆ្នាំ ២០២៤, ហើយត្រូវបានរំពឹងថានឹងវិលត្រលប់ទៅរកនិន្នាការធម្មតាវិញ ក្នុងអត្រាកំណើន ២,១% ក្នុងឆ្នាំ ២០២៦ ដោយសារការបន្តមានប្រក្រតីភាពនៃថ្លៃទំនិញសកល ជាពិសេសថ្លៃប្រេងអន្តរជាតិ ។ អត្រាប្តូរប្រាក់ជាមធ្យម រំពឹងថានឹង

ស្ថិតក្នុងរង្វង់ ៤ ០៥៤ និង ៤ ០៥២ រៀល ក្នុងមួយដុល្លារអាម៉េរិក ដោយសារការបន្តអនុវត្តវិធានការគោលនយោបាយ សំដៅធានានូវស្ថិរភាពនៃអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា ។

ក្នុងរយៈពេលមធ្យមខាងមុខ (២០២៧-២០២៨), សេដ្ឋកិច្ចកម្ពុជា ត្រូវបានរំពឹងថាចាប់ផ្តើមងើបឡើងវិញសន្សឹម ក្នុងអត្រាកំណើនជាមធ្យមប្រមាណ ៥,៦% ដោយសារការរំពឹងទុកការងើបឡើងវិញជាបណ្តើរៗនៃវិស័យបម្រើការនាំចេញ គួបផ្សំនឹងការកែតម្រូវជាបន្តបន្ទាប់ (Adjustment) នៃទីផ្សារ, ទាំងការនាំចេញរបស់កម្ពុជា ក្នុងវិស័យកាត់ដេរ និងកម្មន្តសាលមិនមែនកាត់ដេរ ជាពិសេសការពង្រីកទីផ្សារថ្មីក្រៅពីទីផ្សារសហរដ្ឋអាម៉េរិក, ក៏ដូចជាការបន្សាំខ្លួនបានទៅនឹងវិបត្តិ/ផលប៉ះពាល់ នៃបណ្តាវិស័យសេដ្ឋកិច្ច ក៏ដូចជាអាជីវកម្មទូទៅ ។ គួរឱ្យកត់សម្គាល់ថា, សម្ទុះកំណើនក្នុងរយៈពេលមធ្យមទៅខាងមុខ (ក្នុងបរិការណ៍នៃការអនុវត្តពន្ធគយបដិការ) របស់កម្ពុជា គឺមានសភាពយឺតបើធៀបនឹងការគិតគូរក្នុងបរិការណ៍មុនគោលនយោបាយពន្ធគយបដិការ (ជាមធ្យមប្រមាណ ៦,៥%) សបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ពីទំហំនៃផលប៉ះពាល់ និងស្លាកស្នាមយ៉ាងជ្រៅលើការនាំចេញ និងវិស័យចន្ទល់កំណើនរបស់សេដ្ឋកិច្ចជាតិ ខណៈដែលល្បឿននៃការធ្វើពិពិធកម្ម និងសមត្ថភាពនៃការបង្វែរទីផ្សារនាំចេញរបស់កម្ពុជាក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ នៅមានកម្រិត ។ ក្នុងន័យនេះ, ការពន្លឿនការអនុវត្តវិធានការ និងគោលនយោបាយជំរុញភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និងពង្រឹងភាពធន់នៃសង្គម-សេដ្ឋកិច្ច ជាពិសេសការពង្រឹងការអនុវត្តនូវ **«យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១»** និងការដាក់ឱ្យអនុវត្តនូវ **«កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និង ពង្រឹងភាពធន់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចនៅក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់ ឆ្នាំ ២០២៥-២០២៨»** និងគោល-នយោបាយពាក់ព័ន្ធផ្សេងទៀត នឹងកាន់តែមានសារសំខាន់ជាចលករក្នុងការជំរុញល្បឿន និងគាំពារកំណើនសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យម និងវែងខាងមុខ ។ យ៉ាងណាមិញ, ផលប៉ះពាល់ និងកម្មវិបាកជាក់ស្តែងនៃពន្ធគយបដិការមកលើសេដ្ឋកិច្ច គឺអាស្រ័យលើកត្តាសំខាន់ៗមួយចំនួន ដូចជា៖ (១). លទ្ធផលជាក់ស្តែងនៃការចរចាររវាងកម្ពុជា ជាមួយនឹងសហរដ្ឋអាម៉េរិក; (២). អត្រាពន្ធដែលត្រូវបានអនុវត្តចំពោះបណ្តាប្រទេសផ្សេងៗដែលជាដៃគូប្រកួតប្រជែងរបស់កម្ពុជា; និង (៣). លទ្ធភាពនៃការបង្វែរប្រវាក់ផលិតកម្ម និងពាណិជ្ជកម្ម; ជាដើម ។

ជារួម, សេដ្ឋកិច្ចកម្ពុជា ក៏ដូចជាសេដ្ឋកិច្ចរបស់បណ្តាប្រទេសនានាលើសកលលោកផងដែរ គឺនៅបន្តហ៊ុមព័ទ្ធដោយអន្តរកាលនៃពហុវិបត្តិ ដែលមានទំនោរទៅរកហានិភ័យ ច្រើនជាកាលានុវត្តភាព ។ ភាពមិនប្រាកដប្រជាពីកត្តាខាងក្រៅអាចនឹងមានកម្មវិបាកជាអវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជា, ដោយផ្ទាល់ និងប្រយោល, ត្បិតកម្ពុជាមានសេដ្ឋកិច្ចតូច ហើយបើកចំហរ និងកាន់តែផ្សារភ្ជាប់ខ្លាំងជាមួយប្រវាក់-ផលិតកម្មក្នុងតំបន់ និងសកល ។ ក្នុងរយៈពេលមធ្យមខាងមុខ, សេដ្ឋកិច្ចកម្ពុជា អាចនឹងជួបប្រទះនឹងហានិភ័យ និងភាពមិនប្រាកដប្រជាចម្បងៗ ដែលបង្កឡើងដោយកត្តាខាងក្រៅ និងកត្តាខាងក្នុង រួមមាន៖

(១). ការបន្តកើនឡើងនូវចរន្តគាំពារនិយម (Protectionism) ជាពិសេសប្រទេសជាមហាអំណាចនានា តាមរយៈគោលនយោបាយសេដ្ឋកិច្ច និងពាណិជ្ជកម្ម ឧទា. ការបន្តដំឡើងពន្ធគយ (Tariffs) ខ្ពស់ជាងការរំពឹងទុក ភ្លាមៗ និង មិនច្បាស់លាស់; (២). ភាពតានតឹងនៃកត្តាភូមិសាស្ត្រសេដ្ឋកិច្ចដែលអាចបន្ទច់បង្អាក់ដល់ច្រវាក់ផ្គត់ផ្គង់សកល និងនាំទៅដល់ការកើនថ្លៃទំនិញជាអន្តរជាតិ; (៣). លទ្ធភាពនៃការថមថយសន្ទុះកំណើនសេដ្ឋកិច្ចប្រទេសជាដៃគូពាណិជ្ជកម្ម និងប្រភពវិនិយោគ; (៤). ការកើនឡើងសម្ពាធបំណុលសាធារណៈ; (៥). ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ច និងពាណិជ្ជកម្ម; និង (៦). ផលប៉ះពាល់កាន់តែធ្ងន់ធ្ងរពីការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ។ ក្នុងន័យនេះ, ជាទិសដៅយុទ្ធសាស្ត្រ និងគោលនយោបាយអាទិភាព, រាជរដ្ឋាភិបាលនៅតែបន្តប្រកាន់ខ្ជាប់នូវអភិក្រមចំនួន ២ នោះគឺ ៖ (១). វិធានការគោលនយោបាយឆ្លើយតបទៅនឹងបញ្ហាបន្ទាន់ចំពោះមុខ និងក្នុងរយៈពេលខ្លី ដោយផ្តោតលើការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងការធានាលំនឹងជីវភាពរបស់ប្រជាជន; និង (២). ទិសដៅវិធានការគោលនយោបាយរយៈពេលមធ្យម និងវែងខាងមុខ ដែលនឹងផ្តោតលើការដោះស្រាយបញ្ហាជារចនាសម្ព័ន្ធ ក្នុងការជំរុញការធ្វើពិពិធកម្ម ការលើកកម្ពស់ភាពប្រកួតប្រជែង និងការកសាងភាពធន់ សម្រាប់សង្គម-សេដ្ឋកិច្ចកម្ពុជា ។